ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៦..សសរ.

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មការជំនួយការ នៃគណៈកម្មាធិការរៀបចំកិច្ចប្រជុំបូកសរុប ដកពិសោធន៍សកម្មភាព ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្ត កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់ កាលទី៣របស់រាជរដ្ឋាភិបាល កម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋានដើម្បី ត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា

- យោងសេចក្តីសម្រេចលេខ១៤សសរ ចុះថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំ កិច្ចប្រជុំបូកសរុប ដកពិសោធន៍សកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្ត កម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា

**សម្រេច**

**ប្រការ១ .-**

បង្កើតអនុគណៈកម្មការជំនួយការ នៃគណៈកម្មាធិការរៀបចំ កិច្ចប្រជុំបូកសរុប ដកពិសោធន៍សកម្មភាព ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាដែលមានដូចខាងក្រោម៖

I. **អនុគណៈកម្មការឯកសារ**

| | | |
|---|---|---|
| ១-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម **លេខ ទី** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៣-ឯកឧត្តម **ប៉ាវ ហមផាន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៤-ឯកឧត្តម **ម៉ាន់ ចំរើន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៥-ឯកឧត្តម **ថៅ សេដ្ឋាណា** | អនុរដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | **អនុប្រធាន** |
| ៦-ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៧-ឯកឧត្តម **រស់ ករុណា** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៨-លោកជំទាវ **ឡាយ អូនរី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | **សមាជិក** |
| ៩-លោក **ឆាន់ ចន្ទសុភក្តិ** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងសរុប នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | **សមាជិក** |

**អនុគណៈកម្មការនេះមានភារកិច្ចៈ** រៀបចំរបាយការណ៍លទ្ធផលការងាររយៈពេលមួយឆ្នាំ២០១៤ នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា និងទិសដៅបន្តឆ្នាំ២០១៥។ រៀបចំសុន្ទរកថាបើកនិងសុន្ទរកថាបិទ រៀបចំគំរូរបាយការណ៍ ព្រមទាំងធ្វើតំរោងចំណាយផ្សេងៗ សម្រាប់អនុគណៈកម្មការរបស់ខ្លួនជូនទៅអនុគណៈកម្មការផ្គត់ផ្គង់ ។

II. **អនុគណៈកម្មការពិធីការ និងរដ្ឋបាល**

| | | |
|---|---|---|
| ១-ឯកឧត្តម **លូ រ៉ាមីន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម **រាជ សុភន្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | **អនុប្រធាន** |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ៅ ភក្តិ** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន និងជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | **អនុប្រធាន** |

| | | |
|---|---|---|
| ៤-លោកជំទាវ **សុខ ស៊ីផន** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រីនិងជាប្រធានស្តីទីនាយកដ្ឋានពិធីការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៥-លោកស្រី **លឹម តិត្យា** | អនុប្រធាននាយកដ្ឋានពីធីការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-លោកឧត្តមសេនីយ៍ត្រី **ខេង សៅវិបុត្ត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៧-លោក **ហាន្យ សុផល** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨-លោក វរៈសេនីយ៍ត្រី **ហោ ស៊ីដែត** | ប្រធានការិយាល័យពិធីការ ក្រសួងមហាផ្ទៃ | សមាជិក |

**អនុគណៈកម្មការមានភារកិច្ចៈ** កំណត់សមាសភាពសមាជិកត្រូវអញ្ជើញដោយសមាមាត្រទៅនឹងសាលប្រជុំ។ អញ្ជើញ និងទទួលបដិសណ្ឋារកិច្ចគណៈអធិបតី សមាជិក សមាជិកា និងភ្ញៀវចូលរួមប្រជុំ អ្នកកាសែត អ្នកយកព័ត៌មានវិទ្យុ ទូរទស្សន៍ កាន់កម្មវិធី រៀបចំសាលប្រជុំ ស្រង់វត្តមាន បែងចែកឯកសារ និងរៀបចំកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់កិច្ចប្រជុំទាំងមូល ព្រមទាំងធ្វើគំរោងចំណាយផ្សេងៗសម្រាប់អនុគណៈកម្មការរបស់ខ្លួនជូនទៅអនុគណៈកម្មការផ្គត់ផ្គង់ ។

### III. អនុគណៈកម្មការការពារ សន្តិសុខ និងសណ្តាប់ធ្នាប់

| | | |
|---|---|---|
| ១-ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ | ប្រធាន |
| ២-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក **ជួនសុវណ្ណ** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជាស្នងការ នៃស្នងការដ្ឋានរាជធានីភ្នំពេញ | អនុប្រធាន |
| ៤-ឯកឧត្តមឧត្តមសេនីយ៍ឯក **ទូច ណារ៉ុថ** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ៥-លោកឧត្តមសេនីយ៍ទោ **រ័ត្ន ស្រ៊ាង** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេសនិងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | សមាជិក |
| ៦-លោកឧត្តមសេនីយ៍ទោ **សំ សាមឿន** | មេបញ្ជាការការពារសន្តិសុខ ទីស្តីការ គណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-លោកឧត្តមសេនីទោ **អែល សំនៀង** | ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ | សមាជិក |
| ៨-លោកឧត្តមសេនីយ៍ត្រី **ឡេង ហុង** | មេបញ្ជាការរងការពារសន្តិសុខ ទីស្តីការ គណៈរដ្ឋមន្ត្រី | សមាជិក |

**អនុគណៈកម្មការនេះ មានភារកិច្ចៈ** ការពារសន្តិសុខ សុវត្ថិភាព និងរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ ធ្វើគំរោងចំណាយផ្សេងៗសម្រាប់អនុគណៈកម្មការរបស់ខ្លួនជូនអនុគណៈកម្មការផ្គត់ផ្គង់ ។

### IV. អនុគណៈកម្មការផ្គត់ផ្គង់

| | | |
|---|---|---|
| ១-ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ ម៉ុនណារិន** | អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តមឧត្តមសេនីយ៍ឯក **ឯម សំណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភា និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | អនុប្រធាន |

| | | |
|---|---|---|
| ៣-ឯកឧត្តម **សេង យូអ៊ាន់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារនិង ហិរញ្ញវត្ថុ និងជាប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្នែកស៊ីវិល ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-ឯកឧត្តមឧត្តមសេនីយ៍ឯក **ច័ន្ទ សុវណ្ណា** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-លោកឧត្តមសេនីយ៍ត្រី **យស់ ធីរៈ** | អនុប្រធានលេខាធិការ នៃលេខាធិការដ្ឋាន អគ្គនាយកដ្ឋានភស្តុភានិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-លោកឧត្តមសេនីយ៍ត្រី **ជា សុគន្ធា** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្នែកសន្តិសុខ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦-លោក **ហួត ដារិត** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | សមាជិក |

**អនុគណៈកម្មការនេះមានភារកិច្ចៈ** បូកសរុបរាល់គម្រោងចំណាយនានា ដែលបម្រើដល់ការរៀបចំអង្គប្រជុំនេះ ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ សម្រេច។

**ប្រការ២ .-**

អនុគណៈកម្មការនីមួយៗ មានសិទ្ធិចាត់តាំងមន្ត្រីក្រោមឱវាទ ដើម្បីជួយការងារតាមការចាំបាច់។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៥

ជ.ប.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

**ស ខេង**

*កន្លែងទទួលៈ*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*